**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# កិច្ចប្រជុំរួមប្រចាំខែសីហា ឆ្នាំ២០២០
# ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី

ព្រឹកថ្ងៃពុធ ១៥កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអញ្ជើញជាអធិបតី ដឹកនាំកិច្ចប្រជុំរួមប្រចាំខែសីហា ឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ជាអនុប្រធាន ទីប្រឹក្សា អគ្គលេខាធិការ នាយក-នាយករងខុទ្ទល័យ អគ្គលេខាធិការ-រង ប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាន សរុបចំនួន៤៥ រូប(ស្ត្រី៤រូប) ដើម្បីពិនិត្យលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី មានប្រសាសន៍ស្វាគមន៍ ដល់មន្ត្រីរាជការទាំងអស់ដែលបានចូលរួម និងបានជម្រាបជូនពីរបៀបវារៈនៃកិច្ចប្រជុំ ព្រមទាំងបញ្ហាផ្សេងៗ។ បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតជូន ឯកឧត្តម **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ ធ្វើរបាយការណ៍ស្តីពីលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែសីហា ឆ្នាំ២០២០ និងលើកទិសដៅសម្រាប់ខែកញ្ញា។

ដោយមានការអនុញ្ញាតពី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ បានធ្វើបទបង្ហាញដោយផ្តោតលើចំណុចសំខាន់ៗស្តីពីលទ្ធផលសកម្មភាពការងារដូចខាងក្រោម ៖

១) សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
២) សមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
៣) បញ្ហាប្រឈមផ្សេងៗ។
៤) ជំហានបន្តសម្រាប់ខែបន្ទាប់។

នៅក្នុងសេចក្តីរាយការណ៍នោះ ឯកឧត្តមអគ្គលេខាធិការ បានរៀបរាប់ពីមេរៀនបទពិសោធន៍ក្នុងការអនុវត្តសកម្ម មួយចំនួនដូចខាងក្រោម ៖

- ការកើនឡើងករណីឆ្លងមេរោគអេដស៍ ភាគច្រើនលើក្រុមប្រឈម (ប្រជាជនគន្លឹះ) គឺក្រុមបុរសរួមភេទជាមួយបុរស (MSM) ដែលមានអាយុវ័យក្មេង។
- បានណែនាំដល់ថ្នាក់ដឹកនាំតាមខេត្តនានាឱ្យអនុវត្តតាមលិខិតលេខ១៣៩ និងការអនុវត្តសកម្មភាពខ្លះមិនចាំបាច់ប្រើថវិកា (ឧទាហរណ៍ បើចុះផ្សព្វផ្សាយគ្រឿងញៀន ត្រូវបញ្ជ្រាបការងារអេដស៍រួមជាមួយផង)

- មានការលំបាកខ្លះទាក់ទងទៅនឹងអ្នកបោះបង់ការព្យាបាល អ្នកស្លាប់ និងការដឹកជញ្ជូនសំណាកឈាម មកវិភាគនៅភ្នំពេញ ដោយសារអ្នកទទួលបន្ទុកការងារនេះបានបាត់បង់ជីវិត (ខេត្តក្រចេះ) ហើយអង្គការ AHF ជាអ្នកឧបត្ថម្ភគាំទ្រ មិនបានផ្តល់ថវិកា ក្នុងអំឡុងពេលជំងឺកូវីដ១៩ ដែលកំពុងរាតត្បាត ដូច្នេះគាត់មិនទាន់បានដំណើរការនៅឡើយ។
- នាយកដ្ឋានទាំងអស់ អនុវត្តការងារបានល្អ មានការទទួលខុសត្រូវខ្ពស់ និងមានសមត្ថភាពដឹកនាំ ក្នុងការបើកវគ្គបណ្តុះបណ្តាល និងផ្ទេរការងារដល់អនុប្រធាននាយកដ្ឋានអនុវត្តបន្ត។

ជាកិច្ចបន្តនៅក្នុងរបៀបវារៈទី២ ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតជូនឯកឧត្តម **ឆា ឆលា** អនុប្រធានអ.ជ.ប.ជ.អ ធ្វើបទបង្ហាញអំពី ៖

ការអនុវត្តសេចក្តីជូនដំណឹងលេខ២១៣ សជណ.សសក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅខេត្តកំពង់ស្ពឺ។ ដោយទទួលបានការអនុញ្ញាត ឯកឧត្តម **ឆា ឆលា** បានរាយការណ៍ជូនអង្គប្រជុំដូចតទៅ៖

## ១- បច្ចុប្បន្នភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ :

- ដោយឈរលើផែនការយុទ្ធសាស្ត្រជាតិទាំង៤៖ យុទ្ធសាស្ត្រទី១) ផ្តល់ការបង្ការ ថែទាំ ព្យាបាល និងគាំទ្រទូលំទូលាយ តាមរយៈវិធីសាស្ត្រពហុវិស័យ យុទ្ធសាស្ត្រទី២)បញ្ចូលការឆ្លើយតបនៃមេរោគអេដស៍ទៅក្នុងប្រព័ន្ធសុខាភិបាល និងវិស័យផ្សេងទៀត យុទ្ធសាស្ត្រទី៣) ពង្រីកវិសាលភាពកិច្ចគាំពារសង្គម និងលើកកម្ពស់ការទទួលបានសេវា និងច្បាប់ យុទ្ធសាស្ត្រទី៤) បង្កើនថវិការបស់រាជរដ្ឋាភិបាលដល់៥០% នៃហិរញ្ញប្បទានឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងផ្តល់ថវិកាដល់អង្គការសង្គមស៊ីវិល។
- ត្រូវទប់ស្កាត់ករណីឆ្លងថ្មីឱ្យនៅត្រឹម៣០០នាក់ក្នុងមួយឆ្នាំ និងទប់ស្កាត់ការស្លាប់ឱ្យនៅត្រឹម ១,០០០នាក់ក្នុងមួយឆ្នាំ។
- មានអ្នកផ្ទុកមេរោគអេដស៍ចំនួន១៤.០០០នាក់ ដែលជាអ្នកមិនទាន់បានព្យាបាល និងមិនទាន់មានក្នុងប្រព័ន្ធសុខាភិបាល ពួកគាត់ គឺជាប្រភពចម្លងទៅអ្នកដទៃ។
- ករណីឆ្លងមេរោគអេដស៍ថ្មី ភាគច្រើនក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរស (MSM) ដែលមានវ័យក្មេង (អាយុក្រោម២៥ ឆ្នាំ) មានរហូតដល់៣២% ។
- ត្រូវពង្រឹងប្រព័ន្ធទំនាក់ទំនងពីថ្នាក់ជាតិ ទៅថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ។
- ការធ្វើវិមជ្ឈការ គឺជាការល្អប្រសើរ ដែលបានប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។

## ២- វឌ្ឍនភាពនៃការអនុវត្តន៍សជណ២១៣ :

ត្រូវអនុវត្តតាមគោលនយោបាយទាំង៦ នៃសេចក្តីជូនដំណឹងលេខ២១៣ សជណ.សស ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ៖

- គោលនយោបាយទី១: ការដាក់បញ្ចូល ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងផែនការវិនិយោគ និងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់។
- គោលនយោបាយទី២: អ្នកផ្ទុកមេរោគអេដស៍ ជាប្រជាជនងាយរងគ្រោះ ដែលត្រូវទទួលអត្តសញ្ញាណប័ណ្ណគ្រួសារក្រីក្រ (ID Poor) និងមូលនិធិសមធម៌។
- គោលនយោបាយទី៣: មន្ទីរពេទ្យ និងមណ្ឌលសុខភាព មានថវិកា សម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍។
- គោលនយោបាយទី៤: ការផ្តល់ថវិកាជូនសង្គមស៊ីវិល ដែលធ្វើការងារអេដស៍។

- គោលនយោបាយទី៥: ជានាលំហូរថវិកាសម្រាប់ចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍។
- គោលនយោបាយទី៦: ការធ្វើសមាហរណកម្មនៃសេវាថែទាំមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងប្រព័ន្ធសុខាភិបាល។
- បានរៀបចំសិក្ខាសាលាស្តីពី ការអនុវត្តសេចក្តីជូនដំណឹងលេខ២១៣ សជណ.សស ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅខេត្តកំពង់ស្ពឺ ដែលមានការចូលរួមពី អភិបាល-អភិបាលរងនៃគណៈអភិបាលខេត្ត ប្រធានក្រុមប្រឹក្សាខេត្ត នាយករដ្ឋបាលសាលាខេត្ត ប្រធានមន្ទីរដែលពាក់ព័ន្ធជុំវិញខេត្តកំពង់ស្ពឺ កងកំលាំងទាំងបី អភិបាលស្រុកទាំង៨ ប្រធានការិយាល័យគាំទ្រផែនការឃុំក្នុងស្រុកទាំង៨ ប្រធានការិយាល័យស្រុកប្រតិបត្តិទាំង៤ និងអនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាននៃអ.ជ.ប.ជ.អ នាយកមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ ស្មៀនឃុំព្រែកអំបិល ខេត្តកណ្តាល និងកាមរោគព្រមទាំង តំណាងអង្គការ UNAIDS HP+ HACC ។

បន្ទាប់មក កិច្ចប្រជុំបានដំណើរការបន្តនៅក្នុងរបៀបវារៈទី៣ ក្នុងនោះឯកឧត្តមទេសរដ្ឋមន្ត្រី បានមានប្រសាសន៍សំណេះសំណាល និងផ្តល់នូវអនុសាសន៍លើចំណុចសំខាន់ៗដូចខាងក្រោម ៖

១) ការដឹកជញ្ជូនសំណាកឈាម មិនត្រូវរងចាំអង្គការណាមួយ ដើម្បីផ្តល់ថវិកានោះទេ ត្រូវណែនាំពួកគាត់ឱ្យចេះកែច្នៃក្នុងការដឹកជញ្ជូនសំណាកឱ្យទៅដល់គោលដៅ។

២) ឯកឧត្តមជាទីប្រឹក្សា ត្រូវមានវត្តមានចាំបាច់ រាល់ការកោះអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ បើសិនជាមានធុរៈចាំបាច់ត្រូវស្នើសុំការអនុញ្ញាតច្បាប់ពីឯកឧត្តមទេសរដ្ឋមន្ត្រី ក្នុងករណីផ្ទុយពីការណែនាំ ត្រូវទទួលខុសត្រូវខ្លួនឯង។

៣) សូមកោតសរសើរចំពោះ មន្ត្រីរាជការ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ច ក្នុងអំឡុងពេលជំងឺកូវីដ១៩ កំពុងរាតត្បាតនេះ។

៤) សូមលើទឹកចិត្តឱ្យបន្តដល់កម្មវិធីពង្រឹងសមត្ថភាព ដែលបានអនុវត្តកន្លងមក ដោយមានការសម្របសម្រួលពីឯកឧត្តម **ហោ ម៉ុនឡេខ** ដើម្បីបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព ដែលជាចំណុចល្អធ្វើឱ្យយើងស្វែងយល់ពីបញ្ហារួចឈានទៅរកដំណោះស្រាយបាន។

៥) ការចុះបំពេញបេសកកម្ម ត្រូវមានកម្មវិធីច្បាស់លាស់ ហើយការងារដែលបានធ្វើ ត្រូវតែមានលទ្ធផល។

៦) ការអនុវត្ត សជណ២១៣ ជាចំណុចសំខាន់ ការធ្វើនៅខេត្តកំពង់ស្ពឺជាការចាប់ផ្តើម ដែលយើងត្រូវយកទៅអនុវត្តនៅខេត្តផ្សេងៗទៀត។ ខេត្តមួយចំនួនធំ មិនទាន់បានយល់ដឹងពីខ្លឹមសារនៃសជណ២១៣នេះទេ ប៉ុន្តែខេត្តមួយចំនួនក៏បានអនុវត្តរួចហើយ។ ផ្តល់សជណ២១៣ ជូនគាត់ ដើម្បីឱ្យអនុវត្ត ទោះជាគ្មានការណែនាំឱ្យមានថវិកាសម្រាប់កម្មវិធីអេដស៍ក្នុងខេត្តរបស់គាត់ក៏ដោយ គឺគាត់ធ្វើបាន។ សជណ២១៣ ជាក្របខ័ណ្ឌច្បាប់ និងបទដ្ឋានគតិយុត្ត ដែលឯកឧត្តមអភិបាលខេត្តយកទៅធ្វើការងារអេដស៍បាន។ ការអនុវត្ត សជណ២១៣ នេះវាត្រូវការពេលវេលាយូរអង្វែងដែលយើងចាប់ផ្តើមពីអន្តរកាល ទៅចីរភាព។

៧) ត្រូវណែនាំ ដល់ថ្នាក់ខេត្ត ថ្នាក់ស្រុក ថ្នាក់ឃុំ ឱ្យអនុវត្តនូវ ៖ ទី១) រៀបចំបង្កើតគណៈកម្មាធិការអេដស៍ ទី២) ណែនាំឱ្យបញ្ជ្រាបផែនការអភិវឌ្ឍឃុំ សង្កាត់ ៣ឆ្នាំ និង៥ឆ្នាំ។

៨) រកឱ្យឃើញករណីឆ្លងថ្មី និងទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ បើសង្ស័យត្រូវធ្វើការណែនាំឱ្យធ្វើតេស្តឈាម ធ្វើការព្យាបាលដោយប្រើថ្នាំ និងការការពារដោយប្រើស្រោមអនាម័យ។

៩) ឯកឧត្តម លោកជំទាវ អនុប្រធាន ដែលមានការទទួលខុសត្រូវជាមួយនឹងខេត្ត ត្រូវត្រៀមចុះតាមខេត្តនានា ដើម្បីធ្វើបទឧទ្ទេសនាម ដែលតម្រូវឱ្យមាន ឯកសារ ដូចជា ៖ សជណ២១៣ អនុក្រឹត្យលេខ១៩៣ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ហៅថា **វិមជ្ឈការ** និងសៀវភៅណែនាំស្តីពីការ

អនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់។ មុននឹងចុះទៅអនុវត្តការងារតាមខេត្ត សូម ឯកឧត្តម **ឆា ផលា** ធ្វើការណែនាំអំពីរបៀបរបបនៃការអនុវត្ត។ ចំពោះខេត្ត ក្រុងដែលបានចុះហត្ថលេខា ក្នុងការអនុវត្តការពន្លឿនទីក្រុងឆ្លើយតបនឹងមេរោគអេដស៍ ( Fast track Cities ) មានរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ឯកឧត្តមទេសរដ្ឋមន្ត្រីនឹងរៀបចំអនុវត្តដោយផ្ទាល់។

១០ ) តាមដានពីអត្តសញ្ញាណអ្នកក្រីក្រដែលមានផ្ទុកមេរោគអេដស៍ បានទទួលមូលនិធិសមធម៌ពីរាជរដ្ឋាភិបាលឬនៅ? មានឈ្មោះនៅក្នុងប្រព័ន្ធសុខាភិបាលហើយឬនៅ?

១១ ) ត្រូវមានសេចក្តីប្រកាសអន្តរក្រសួងលេខ១៨២ ស្តីអំពីល័ក្ខខ័ណ្ឌហិរញ្ញវត្ថុ ល័ក្ខខ័ណ្ឌបច្ចេកទេស និងនិតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុ មានភ្ជាប់ល័ក្ខខ័ណ្ឌទៅឱ្យរដ្ឋបាលខេត្ត សម្រាប់អនុវត្តមុខនាទីគ្រប់គ្រង និងផ្តល់សេវា។

១២ ) ឯកឧត្តមទេសរដ្ឋមន្ត្រី បានចេញនូវសេចក្តីណែនាំដល់ ឯកឧត្តម លោកជំទាវ ដោយបែងចែកក្រុមការងារឱ្យទទួលខុសត្រូវក្នុងការសម្របសម្រួលសិក្ខាសាលាស្តីពី ការអនុវត្តសេចក្តីជូនដំណឹងលេខ២១៣ សជណ.សស ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅស្រុកទាំង៨ នៃខេត្តកំពុងស្ពឺ។

១៣ ) ត្រៀមរៀបចំកិច្ចប្រជុំពេញអង្គនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ និងសន្និបាតបូកសរុបការងារប្រចាំឆ្នាំ២០២០ រយៈពេល២ថ្ងៃ។ អ្នកដែលត្រូវធ្វើបទបង្ហាញ ត្រូវមកបង្ហាញនៅសាលប្រជុំ នៃអ.ជ.ប.ជ.អ។ ចំណែកគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមក្រសួង ខេត្ត និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ត្រូវអញ្ជើញចូលរួមតាមវីដេអូខនហ្វឺរេន។

១៤ ) ទិវា១ធ្នូ ត្រូវរៀបចំធ្វើតាមវីដេអូខនហ្វឺរេន កម្មវិធីធ្វើនៅ អ.ជ.ប.ជ.អ មាននិមន្តព្រះសង្ឃ អញ្ជើញតំណាងអ្នកផ្ទុកមេរោគអេដស៍ និងមន្ត្រីទាំងអស់នៃអ.ជ.ប.ជ.អ។ រៀបចំសាររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ** (ដោយអានសារ) និងសាររបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដោយស្នើសុំឱ្យមានការចាកផ្សាយតាមទូរទស្សន៍។ មុនឈានចូលដល់ទិវា១ធ្នូនេះ សុំឱ្យស្ថានប័នជាតិ ឬស្ថាប័នក្រៅរដ្ឋាភិបាល ឱ្យផលិតរឿងខ្លីៗ ( Spot ) អំពីជំងឺ អេដស៍ ឱ្យបានច្រើន និងឱ្យមានវេទិកាតុមូល ដោយមានកិច្ចសម្ភាសន៍។

១៥ ) រាល់ការរៀបចំកម្មវិធីដែលមានការជួបជុំគ្នាជាក្រុម ត្រូវជៀសវាងកុំឱ្យមានសមាជិកចូលរួមលើសពី៥០នាក់ ដោយអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល។

១៦ ) រៀបចំឱ្យមានអ្នកតំណាងអ្នកផ្ទុកមេរោគអេដស៍ទូទាំងប្រទេស ដែលជាដៃគូរបស់អ.ជ.ប.ជ.អ ហើយពួកគាត់អាចចូលរួមគ្រប់វេទិការ។

នៅទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការងារឱ្យបានកាន់តែប្រសើរឡើង។ លើសពីនេះទៅទៀត ត្រូវយកលទ្ធផលជាធំ រកឱ្យឃើញករណីឆ្លងថ្មី និងទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ បើសង្ស័យត្រូវធ្វើការណែនាំឱ្យធ្វើតេស្តឈាម ធ្វើការព្យាបាលដោយប្រើថ្នាំ និងការការពារដោយប្រើស្រោមអនាម័យ យើងទាំងអស់គ្នាត្រូវប្តេជ្ញាអនុវត្តការងារឱ្យទទួលបានជោគជ័យ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១:១២ នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃព្រហស្បតិ៍ ១រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០

| | |
|---|---|
| **បានឃើញ និងឯកភាព** | **អ្នកធ្វើកំណត់ហេតុ** |
| **ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ** | **នាយកខុទ្ទកាល័យ** |





